# សិលាចារឹកវត្តហ្លួងកៅ (តំបន់វត្តភូ)

នៅក្នុងបរិបទនៃការសិក្សាស្រាវជ្រាវសិលាចារឹកខ្មែរ គេដឹងច្បាស់ថា សិលាចារឹកវត្តគំនូរ ឬហៅថាសិលាចារឹកអង្គរបុរី (K.600) គឺជាសិលាចារឹកសរសេរជាភាសាខ្មែរបុរាណដ៏ចំណាស់ជាងគេ ដោយមានការបញ្ជាក់ប្រាប់អំពីកាលបរិច្ឆេទច្បាស់លាស់នៅក្នុងមហាសករាជឆ្នាំ៥៣៣ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៦១១។ ផ្ទុយទៅវិញ សិលាចារឹកសរសេរជាភាសាសំស្ក្រឹតដែលចំណាស់ជាងគេរបស់ខ្មែរ មិនមានបញ្ជាក់ប្រាប់អំពីកាលបរិច្ឆេទជាក់លាក់ឡើយ។ ប៉ុន្តែ អ្នកស្រាវជ្រាវជាច្រើនយល់ថា សិលាចារឹកវត្តហ្លួងកៅ (K.365) ជាសិលាចារឹកភាសាសំស្ក្រឹតចំណាស់ជាងគេ។ តើសិលាចារឹកវត្តហ្លួងកៅ មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្តេចខ្លះ?

សិលាចារឹកវត្តហ្លួងកៅ ឬខ្លះហៅថា សិលាចារឹកទេវានីក រកឃើញនៅដើមស.វ.ទី២០ ដោយអ្នកស្រាវជ្រាវជនជាតិបារាំងឈ្មោះ Lunet De Lajonquière នៅក្នុងបរិវេណវត្តហ្លួងកៅ ស្ថិតនៅក្នុងភូមិហ្លួងកៅ ខេត្តចាម្ប៉ាសាក់ ភាគខាងត្បូងប្រទេសឡាវ។ វត្តហ្លួងការ ស្ថិតនៅក្នុងបរិវេណក្រុងបុរាណរបស់ខ្មែរនាសម័យមុនអង្គរក្នុងរាជ្យព្រះបាទស្រេស្ឋវរ្ម័ន ហើយនៅក្នុងឆ្នាំ១៩៦១ អ្នកស្រាវជ្រាវឈ្មោះ Archaimbat Charles បានហៅទីក្រុងនេះថា "**ស្រេស្ឋបុរ**" ដែលជាទីក្រុងស្ថិតនៅតាមបណ្តោយទន្លេមេគង្គ ភាគខាងកើតប្រាសាទវត្តភូចម្ងាយប្រមាណ ៣ គីឡូម៉ែត្រ។ ក្នុងឆ្នាំ១៩១៣ លោក Henri Parmentier បានរៀបរាប់ថា សិលាចារឹកនេះមិនអាចអានបានទាល់តែសោះ *(cette stèle est complètement illisible)*។ មកដល់ឆ្នាំ១៩២៣ អ្នកស្រាវជ្រាវសិលាចារឹកខ្មែរដ៏ល្បីល្បាញឈ្មោះ George Coedès និងលោក Henri Parmentier បានចុះបញ្ជីសិលាចារឹកនេះលេខ K.365 ហើយលោក George Coedès បានបោះពុម្ពផ្សាយការបកប្រែសម្រួលខ្លឹមសារសិលាចារឹកនេះទាំងស្រុងជាភាសាបារាំងនៅក្នុងសៀវភៅ "***សិលាចារឹកកម្ពុជា***" ភាគទី៥ ឆ្នាំ១៩៥៣ និងឆ្នាំ១៩៥៦។

សិលាចារឹកវត្តហ្លួងកៅ ចារឹកនៅលើថ្មភក់ជាបង្គោលសីមាមាន៤ជ្រុង ដោយជ្រុងនីមួយៗមានអក្សរចំនួន ១៦ បន្ទាត់ (សរុបចំនួន ៦៤ បន្ទាត់) ជាភាសាសំស្ក្រឹតប្រភេទឆន្ទខុសៗគ្នា ដូចជា ស្រគ្ធរា អនុស្តុប មាលិនី និងចារឹកបែបពាក្យរាយធម្មតាផងដែរ។ ផ្អែកទៅលើទម្រង់ទូទៅនៃអក្សរ (អក្សរទម្រង់សម័យដើមសន្តតិវង្សបល្លវ ស្រុកឥណ្ឌាខាងត្បូង) អ្នកស្រាវជ្រាវជាច្រើនជឿថា

អត្ថបទដោយ៖ កំ វណ្ណាក់ និងព្រះតេជគុណ អេង សុគន្ធ

*សិលាចារឹកនេះគួរតែមានអាយុកាលចំណាស់ជាងសិលាចារឹកអ្នកតាដំបងដែក (K.875) សិលាចារឹកប្រាសាទប្រាំល្វែង (K.5) និងសិលាចារឹកតាព្រហ្មទន្លេបាទី (K.40) ហើយសិលាចារឹកនេះគួរតែមានអាយុកាលនៅរវាងស.វ.ទី៥ ឬដើមស.វ.ទី៦។ ដោយហេតុថា ខ្លឹមសាររបស់សិលាចារឹកវត្តហ្លួងកៅមានរំលេចអំពីមហារាជាធិរាជ (ស្តេចនៃស្តេចទាំងឡាយ) ព្រះនាម "**ទេវានីក**" (កងទ័ពទេវតា) និងនៅជ្រុងទី១នៃសិលាចារឹកមានរំលេចពាក្យ "**ទូរទេស**" (ប្រទេសឆ្ងាយ ឬតំបន់ឆ្ងាយ) អ្នកស្រាវជ្រាវជាច្រើននៅតែមានមន្ទិលនៅឡើយថា តើព្រះបាទទេវានីកជាស្តេចនៃអាណាចក្រណាមួយឱ្យពិតប្រាកដ? ក្នុងនោះ លោក George Coedès ស្នើថា ព្រះមហារាជធិរាជទេវានីក ជាស្តេចនៃអាណាចក្រលីនយី (ចាម្ប៉ា) ដែលជាសម័យកាលប្រវត្តិសាស្ត្ររបស់ចាម្ប៉ាគេស្គាល់តាមកំណត់ហេតុចិន (សព្វថ្ងៃស្ថិតនៅវៀតណាមកណ្តាល)។ ទោះបីជាលោកសន្និដ្ឋានដូច្នេះក៏ដោយ ព្រះនាម "ទេវានីក" គេមិនដែលឃើញចារឹកនៅក្នុងសិលាចារឹកចំណាស់ៗរបស់ ចាម្ប៉ាឡើយ។ ក្រោយមកទៀត នៅឆ្នាំ២០១៥ អ្នកស្រាវជ្រាវជនជាតិរុស្ស៊ី គឺលោក Anton O. ZAKHAROV បានសិក្សាលម្អិតឡើងវិញ និងសន្និដ្ឋានម្តងទៀតថា ព្រះបាទទេវានីក ទំនងគ្រងរាជ្យនៅនគរស្វ័យភាពមួយ ដែលមិនសូវមានលក្ខណៈដូចនគរចេនឡា ចាម្ប៉ា ឬហ្វូណន ស្ថិតនៅតំបន់ទន្លេមេគង្គភាគខាងក្រោម។ ទោះបីជាយ៉ាងណា យើងយល់ថា ការស្នើឡើងរបស់អ្នកស្រាវជ្រាវមុនដែលយល់ថា ព្រះបាទទេវានីកជាស្តេចនៃអាណាចក្រលីនយី (ចាម្ប៉ា) ដោយផ្អែកទៅលើពាក្យ "ទូរទេស" ដែលមានន័យថា តំបន់ឆ្ងាយ ឬប្រទេសឆ្ងាយ វាហាក់ដូចជាមិនសមស្របសោះឡើយ ព្រោះផ្នែកផ្សេងៗទៀតមិនមានអ្វីអាចកំណត់ ឬបញ្ជាក់បានថាទ្រង់ជាស្តេចនៃអាណាចក្រចាម្ប៉ាឡើយ។*

*ផ្នែកដំបូងរបស់សិលាចារឹកវត្តហ្លួងកៅ ឬសិលាចារឹកទេវានីក ជាប្រភេទប្រណាមស្លោកពាក្យនមស្ការដល់ទេពទាំងបីនៃព្រហ្មញ្ញសាសនា គឺព្រះព្រហ្ម ព្រះវិស្ណុ និងព្រះសិវ និងរៀបរាប់ប្រៀបធៀបអំពីសមត្ថភាព និងចំណេះដឹងរបស់ព្រះរាជាជាមួយតួអង្គសំខាន់ៗដែលមានចែងនៅក្នុងមហាវណ្ណកម្មឥណ្ឌាបុរាណ ដូចជា គម្ពីរមហាភារត និងគម្ពីរមហាបុរាណ។ បន្ទាប់មកទៀត ខ្លឹមសារសិលាចារឹកនេះបានរៀបរាប់អំពីព្រះបាទទេវានីកបានកសាង "**មហាតីថ៌**" (កន្លែងសម្រាប់ងូតទឹកលាងជម្រះបាប) ហើយបានប្រតិស្ឋានមហាតីថ៌នេះឱ្យដូចទៅនឹងមហាតីថ៌មួយដែលស្ថិតនៅតំបន់កុរុក្សេត្រ ដែលជាទីស្ថានដ៏ពិសិដ្ឋនៅស្រុកឥណ្ឌាដែលគេជឿថា បាបកម្មនិងពេគា*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

ទាំងឡាយនឹងវសាត់អស់ទៅ បន្ទាប់អំពីផ្ងូតទឹកលាងជម្រះរួចៗ សិលាចារឹកនេះក៏បានបញ្ជាក់បន្ថែមអំពីប្រវត្តិខ្លះៗទាក់ទងនឹងកុរុក្សេត្រ ធម៌ក្សេត្រ និងលក្ខណៈពិសិដ្ឋរបស់ទីស្ថានទាំងនេះ។ មហាតីថ៌នេះមានឈ្មោះថា **"អគ្រមហាស្រីគន្ធកតីថ៌"** *(តីថ៌ស្ថានដ៏ប្រសើរដែលប្រជុំដោយក្លិនក្រអូបនៃមហាសិរីសួស្តី)* ដែលមានមានប្រវែងសរុបកន្លះយោជន៍ *(យោជន៍ជាខ្នាតវាស់ប្រវែងក្នុងជំនឿហិណ្ឌូសាសនា ដែលមួយយោជន៍អាចមានប្រវែងចន្លោះពី ១៣ ដល់ ១៦ គីឡូម៉ែត្រ)*។ នៅខាងចុងស្លោកបានបញ្ជាក់យ៉ាងច្បាស់ថា "ទេវានីក" មិនមានជាព្រះនាមពិតក្នុងរាជសម្បត្តិរបស់ព្រះអង្គនោះទេ ពោល គឺគ្រាន់តែជា **"នាមាភធេយ្យ"** ដែលបានប្រទានដល់ព្រះអង្គតាមរយៈការកសាងទេវប្រសិដ្ឋតែប៉ុណ្ណោះ។ ដូច្នេះ ព្រះនាមរបស់ក្សត្រអង្គនេះនៅក្នុងរាជ្យសម្បត្តិ មិនទាន់មានឯកសារណាមួយអាចពន្យល់បាននោះទេ។

## អត្ថបទចារឹក និងសេចក្តីប្រែ

### ផ្នុងទី១
### សរសេរបែប "ស្រគ្ធរាឆន្ទ"

១. វ្យាមាំ មយាសហស្រញ្ចកជិជមទិលំ យៃស្ត្រិកិផ្ទៃកកាលេ
កច្ចន្ត្យន្ត៌ ជិមគ្នំ ភវសលិលជិដៅ តារយន្តិ ស្មរេ ច
ព្រហ្មោបេន្ទ្រក្វាណាំ សជិទិលមជុជំ សត្វភាវញ្ច តេមា
មាជ្ជន្ទីណាំ ជវេន្ទ្រះ កុកលវិជិមិមំ យក្វការា _ [បិ]ហោតោះ។

**ប្រែថា៖** *សាកលលោកទាំងមូលនេះ មានដំណើរពុតត្បុតប្រែប្រួល* (មាយា?) *រាប់ពាន់បែបក្នុងកាលវេលាមិនមែនតែមួយ* (ហើយថែមទាំងស្ថិត) *ជាមួយនឹងកាលទាំងបី* (អតីត បច្ចុប្បន្ន និងអនាគត) *នៃសង្សារចក្រដ៏អន្តរាយ* (សព្វសត្វ) *ក៏បានទៅកាន់ទីធ្លាក់ចុះដ៏ជ្រៅបំផុតក្នុងមហាសមុទ្រគឺភព* (ហើយពួកទ្រង់) *បានចម្លងនូវមនុស្សជាតិគ្រប់រូប ព្រមទាំងសត្វភាពទាំងឡាយព្រោះហេតុនេះហើយ* (ទើប) *សម្តេចព្រះនរេន្ទ្រាធិបតី បានប្រារព្ធធ្វើនូវពិធីកុសលកម្មនេះឡើងដើម្បី* (ជាការឧទ្ទិសដល់) *ព្រះព្រហ្ម ព្រះឧបេន្ទ្រ* (ព្រះពិស្ណុ) *និងព្រះរៀគ្វរ* (ព្រះឥសូរ) *ដែលជាទីទ្រទ្រង់* (នៃសព្វសត្វ) *នោះ*។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

៤ - ១៦. ឥត្យេវាយំ ត្រិភក្ត្យានារាយណបិតាមហាទិសវ៌្វទេវប្រសាទាភិសិក្តះ បូវ៌្វជាជ៌្ជិតបុណ្យកុសលនិមិត្តសម្ប្រាប្តសវ៌្វកម្មាតិមានុសកម្មា យុធិឞ្ឋិរះ សទ្ធម៌្មស្ថិតោ វិរុធនរបតិរិវ ប្រជាបាលនេ ធនញ្ជយ ឥវ វិបុលរណវិជយេ ឥន្ទ្រយុម្ន ឥវ ក្រិយជ្ញវិធានេ ឝិពិរិវ ទានេ មហាទានេ ភគវន្មហាបុរុសព្រហ្មណ្យតានុចារិរ ព្រហ្មណ្យភាវេ កនកបាណ្ឌ្យ ឥវ ន្យាយរក្សណេ មហោទធិរិវ គាម្ភីយ៌្យេ មេរុរិវ ស្ថៃយ៌្យេ បូវ៌្វមតេន ភគវតា ត្រីលិង្គបវ៌្វតេនាស្មិន ទូរទេសាជ្ជនិតាម្ពិតោ មហាជិរជ្យេត្វយ៌្យេ វិតិម្ពវិស្បម្ពម្ពត្វាក្សរមង្គលនាមធេយោ ទ្វិមទនេកានិកាវាប្តវិជយោ វិជយ ឥវ មហារាជាធិរាជត្រីមាញ្ជូទេវាដីកះ អថាវសំសារសាគរាត្តរណាយ សវ៌្វសត្វានុក្ចិត្យ មហាក្ឆិម[ុ]ខបុរោកមំ សានេកាកោសហស្រ។

ប្រែថា៖ (មានសេចក្តីដំណាលមក) ដូច្នេះថា (ព្រះរាជាអង្គនេះ) ត្រូវបានអភិសេកហើយក្រោមប្រសាទពរជ័យនៃសព្វសារពើអស់ទេពនិករទាំងឡាយ មានជាអាទិ៍ ព្រះបិតាមហ (ព្រះព្រហ្ម) ព្រះនារាយណ (ព្រះវិស្ណុ) និងព្រះត្រីសង្ករ (ព្រះសិវ)។ ទ្រង់ជាអ្នកមានសម្ភាយបុណ្យ ដែលបានសន្សំទុក ហើយប្រកបដោយនិម្មិតដ៏ល្អប្រពៃពន់ពេកតាំងតែពីបុព្វមក។ មិនចាំបាច់ធ្វើពិធិកម្ម(ប្រសិទ្ធី) ទាំងពួងក្តី ក៏ទ្រង់មានព្រះរាជសកម្មភាពជាកំពូលមនុស្ស (ឬជាមនុស្សទេព) រួចស្រេចទៅហើយ។ ព្រះអង្គតាំងនៅស៊ប់ក្នុងព្រះសទ្ធម្ម៌ ប្រដូចទៅនឹងព្រះបាទយុធិឞ្ឋិរ, មានការអភិបាលរក្សាប្រជាជនប្រដូចទៅនឹងព្រះនរបតីពិពុធ (ព្រះឥន្ទ្រ), មានពិជ័យសង្គ្រាមលើអស់ពួកពលសឹកសត្រូវប្រដូចទៅនឹងធនញ្ជ័យ (អជ៌ុន), មានវិធានការលើពិធីបូជាយញ្ញជាច្រើនយ៉ាងប្រដូចទៅនឹងឥន្ទ្រយុម្ន ដែលបានធ្វើទាន និងធ្វើមហាទានប្រដូចទៅនឹងព្រះបាទឝិពិ, មានព្រាហ្មណភាពប្រដូចទៅនឹងព្រះភគវន៑មហាបុរុសព្រហ្មណ្យតានុចារី, (មានការប្រកាន់មាំ) ក្នុងការរក្សាន្យាយ (គឺច្បាប់)ប្រដូចទៅនឹងកនកបាណ្ឌ្យ, មាន (ព្រះប្រាជ្ញា) ជ្រាលជ្រៅប្រដូចទៅនឹងមហាសាគរ និងមានភាពរឹងមាំប្រដូចទៅនឹងភ្នំសុមេរុ។ យោងតាមមតិពីបុព្វមក ព្រះអង្គត្រូវបាននាំមកពីស្រុកទេសឆ្ងាយឱ្យស្ថិតក្នុងរាជ្យដ៏ធំអស្ចារ្យនេះ ដោយ (អំណាចទេពឭទ្ធ៌) ព្រះភគវន៑ត្រីលិង្គបព៌ត។ ទ្រង់មានព្រះនាមាភិធេយ្យដ៏មានសិរីមង្គលប្រកបដោយពាក់កណ្ដាលនៃអក្សរ ៨ ព្យាង្គ (គឺ៤ម៉ាត់) យ៉ាងច្បាស់ និងដ៏ពិសិដ្ឋ។ ទ្រង់បានសម្រេចជ័យជម្នះលើសឹកសត្រូវជាច្រើនអនេក

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ

*លើសលប់ប្រដូចទៅនឹងព្រះបាទពិជ័យ។ ព្រះមហារាជាធិរាជត្រឹមទិត្រីទេវានីក ដើម្បីចម្លងសត្វសព្វសារពើឱ្យចេញចាកពីសាគរគឺសង្សារវដ្តដ៏ធំធេង ទ្រង់បានប្រារព្ធពិធីឧទ្ទិសបូជាចំពោះព្រះមហាអគ្និមុខ (គឺទេវតា ព្រាហ្មណ៍ និងប្រេត) ដែលជាប្រមុខមួយអន្ទើ ដោយសត្វគោរាប់ពាន់ក្បាលជាច្រើនអនេក។*

## ជ្រុងទី២

១ - ៧. ...........................................................................

៨ - ១០. សំវត្តំនំ មហាចាបចារដំ មហាតីត្ថំញ្ចការ..បការនេកក......គវាំ សហស្រែ ...នេ តប៉្បយធាហុតំ ..វ៉្ង.....ស្យ ធា ......នេវ។

ប្រែថា៖ *"ទ្រង់បានអភិវឌ្ឍ ដោយការកសាងមហាតីថ៌ ដែលជាទីលាងជម្រះនូវមហាបាបទាំងពួង....ដោយការបរិច្ចាគសត្វគោជាច្រើនអនេកពាន់ក្បាល .......ញុំាងឱ្យឆ្អែតស្កប់ស្កល់.......។*

២. ...........បុរតប្រែនេត សព៌្វេសុជេឌុរៃរន្នា..[ជិភិះ]
.......ហារីត ........... ប្រតិមាភិផ្ទែកយជ្ញ...ក្ខុន។

ប្រែថា៖ *.....ប្រទេសកាលពីមុន .......... ដោយអភិជនទាំងអស់ មានរត្នសម្បត្តិទាំងឡាយមានមេគោជាដើម ..........ព្រះហារីគ (ហរិ និង ឦគ) =ព្រះវិស្ណុ និងព្រះឥសូរ....ដោយការបូជាយជ្ញដល់ព្រះបដិមា។*

៣. សសនស្សៃទ្ធិផ្ទៃស័ាត្ត៌ មគ្និហោត្រែ....[ U _ មិ ក្ត្វតំ] តធា
ឧត្តមោត្ថរណាំ..[U U វាក្យាំ] ចការ ប្រណិធឹ ធ្នបះ។

ប្រែថា៖ *ក្នុងគ្រានោះ អគ្និហោត្របូជា [ត្រូវបានធ្វើ?] ដោយព្រាហ្មណ៍ទាំងឡាយជាមួយនឹងបរិវារទាំងឡាយរួចហើយ ព្រះនរបតីបានធ្វើការប្រណិធាន [ដោយពាក្យពេចន៍?] រំលេចឡើងយ៉ាងឧត្តមថ្លៃថ្លា (ថា)*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

៤. យន្នយោចាជ្ជិតបុណ្យំ យ..[ត្តួលំ] ទេវ ...[កា]ត្តិតំ
តទេវាស្តុ [តទេវាស្តុ] .......... តីត្ថំឌិ... [ណ៌ាយធំ] ផលមិ។

ប្រែថា៖ *បុណ្យឯណាដែលបានសាងទុកហើយដោយខ្ញុំ [ផលចម្រើនរុងរឿង?]...ឯណាដែលត្រូវបាន...[កោតសរសើរដោយ?] ទេព្តាទាំងឡាយ ចូរសម្រេចបានកុំបីខាន ដល់...... នូវផលបុណ្យ [ដែលសម្រេចចេញ?] ពីតីថ៌ស្ថាននោះ។*

**ជ្រុងទី៣**

៥. យេ វសន្តិ មហាតីត្ថេ តត្រ ច យេ ម្ឫតា ឯរាះ
ស្នវនំ យេ ច កុរ្វន្តិ តត្តួលំ ច្រាប្នុវន្ត [ន្តុ]តេ។

ប្រែថា៖ *ជនទាំងឡាយណាបានរស់នៅក្នុងមហាតីថ៌នេះក្តី ជនទាំងឡាយណាបានស្លាប់ក្នុងទីនោះក្តី ឬជនទាំងឡាយណាបានធ្វើនូវស្នាន (ងូតទឹកជម្រះបាប) ក្តី ផលនោះគប្បីសម្រេចដល់ជនទាំងឡាយនោះ។*

៦. យត្តត្បុណ្យោបមផលំ ប្រកាសានិបុរាក្ឫតេះ
ᑌ _[តស្យ] ឯាម តទេវាត្រ ភវតុ ជ្ឫតមទ្យ មេ។

ប្រែថា៖ *ផលបុណ្យអាចប្រៀបផ្ទឹមបានយ៉ាងណាៗ គឺទៅតាមអ្វីមានក្នុងប្រកាស (គម្ពីរសាស្ត្រា) ជាអាទិ៍ ដែលធ្លាប់ត្រូវបានគេអនុវត្តហើយពីបុរាណកាលមក ពាក់ព័ន្ធនឹងស្ថាននាមនេះ (តស្យនាម?) ដែលត្រូវបានរក្សាទុកមកហើយដល់រូបខ្ញុំរហូតដល់សព្វថ្ងៃនេះ ក៏សូមឱ្យកើតមានតែក្នុងទីស្ថាននេះផងចុះ!*

៧. យេ ទេវា យជ្ញភាគាត៌្ថ មាគតា រោហិតា ឌិរិ
ព្រហ្មោបេន្ទ្រេត្វារាទ្យាស្តេ តន្នាម ប្រិឌិសន្តុ វៃ។

*អត្ថបទដោយ៖ កំ វណ្ណាភ៉ា និងព្រះតេជគុណ អេង សុគន្ធ*

ប្រែថា៖ *ទេពទាំងឡាយឯណាដែលបានអញ្ជើញមក មានពណ៌ក្រហមឆ្អៅព្វដ៏វេហា ដើម្បីទទួលចំណែកនៃការបូជាយញ្ញ ទេពទាំងអម្បាលម៉ាននោះ មាន ព្រះព្រហ្ម ព្រះឧបេន្ទ្រ (ព្រះវិស្ណុ) និងព្រះឦគ្វរ (ព្រះសិវ) ជាអាទិ៍ សូមទ្រង់ប្រោះប្រទាននូវស្ថាននាមផងទានម្ចាស់!*

៨. ឥត្យេវមាធិប្រណិធី　　រាជ្ជុក្កិដ្ឋយតស្តធា
ជាមកតំ កុរុក្សេត្រេ　　....ប្យ ជលៃស្សមមិ។

ប្រែថា៖ *បន្ទាប់ពីបានធ្វើប្រណិធានមានជាអាទិ៍យ៉ាងនេះហើយ គ្រានោះសេចក្ដីរឭកនឹកក្នុងក្នុងព្រះចិន្តា បានប្រាកដដល់ព្រះរាជាឆ្ពោះទៅកាន់ស្ថាននាមក្នុងកុរុក្សេត្រ ....... ដែលមានផល (គឺភាពរុងរឿងចម្រើន) ដូចគ្នា (ទៅនឹងព្រះនគររបស់ព្រះអង្គ)។*

៩. យត្ប្រាំភិហិតំ ស្វគ៌្គំ　　ផលំ ទេវម៉ីគីត្តីតំ
កុរុក្សេត្រេ តទេវាស្តុ　　កុរុក្សេត្រេ ឯវាស្ថិតេ។

ប្រែថា៖ *ស្ថានភាពបែបណាដែលចាស់ទុំពីបុរាណធ្លាប់បានឧទ្ទេសនាមហើយថា ជាស្ថានសួគ៌ មានផល (ភាពរុងរឿងចម្រើន) និងត្រូវបានស្ញើចសរសើរហើយដោយពួកមហាឫមិ និងទេព្តាទាំងឡាយក្នុងកុរុក្សេត្រនោះ ស្ថានភាពទាំងនោះគប្បីកើតមានតែក្នុងកុរុក្សេត្រដែលជាទីស្ថានស្ថិតនៅថ្មីនេះ!*

១០. បុមិណា កុរុណា ប្វរ៌　　_ ∪ [ធម៌]ក្សេត្រក្ខតំ សតាំ
តស្មាជិតិ កុរុក្សេត្រំ　　ខ្យាតំ តីត្ថំ មហាផលមិ។

ប្រែថា៖ *(ទីស្ថាននោះ) ដំបូងឡើយ ត្រូវបានកសាងជា [ធម៌]ក្សេត្រ (ដែលជាទីស្ថានប្រតិបត្តិព្រះធម៌) សម្រាប់សាធុសប្បុរសទាំងឡាយ ដោយមហាឫមីនាម "កុរុ" ព្រោះហេតុនេះហើយ ទើបត្រូវបានដាក់ឈ្មោះថា កុរុក្សេត្រ ដែលជាតីថ៌ស្ថានដ៏មានមហាផល។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

១១. តត្រាបិ កុរុក្សេត្រេ　　វាសុណា សមុទីរិតាះ
　　មហាទុឞ្ក្ឫតកម៌្មាណំ　　ឈយន្តិ បរមាង្គតិម៑។

ប្រែថា៖ *ម្យ៉ាងទៀត ក្នុងស្ថានទីកុរុក្សេត្រនោះ ព្រះវាសុ (ដែលជាតួអង្គរួមនៃទេពនិករទាំង ៨ អង្គ) ទ្រង់ធ្លាប់មានព្រះបន្ទូលហើយថា សូម្បីពួកជនទាំងឡាយដែលធ្លាប់បានប្រព្រឹត្តអំពើបាបកម្មដ៏សែនធ្ងន់ធ្ងរ ក៏តែងតែឆ្ពោះទៅកាន់បរមសុគតិបាន។*

១២. កុរុក្សេត្រង្គមិឞ្យាមិ　　កុរុក្សេត្រេ វសាម្យហំ
　　យេ វសន្តិ កុរុក្សេត្រេ　　តេ វសន្តិ ត្រិវិឞ្ដបេ។

ប្រែថា៖ *ខ្ញុំនឹងទៅកាន់កុរុក្សេត្រ ខ្ញុំនឹងរស់នៅក្នុងកុរុក្សេត្រ ជនទាំងឡាយណារស់នៅក្នុងកុរុក្សេត្រ ជនទាំងឡាយនោះឈ្មោះថា "**កំពុងរស់នៅក្នុងស្ថានសួគ៌**"។*

១៣. ប្ឫថិវ្យាំ នៃមិឞំ បុណ្យំ　　អន្តរីក្សេ តុ បុឞ្ករំ
　　ឆ្ឫចាណាមបិ លោកានាំ　　កុរុក្សេត្រំ វិឝិឞ្យតេ។

ប្រែថា៖ *នៅលើប្រឹថពីនេះ (ក្នុងកុរុក្សេត្រនោះហើយដែលសូម្បីប្រើ) ត្រឹមតែរយៈពេលដ៏ខ្លីក៏អាចសម្រេចបុណ្យបាន ហើយក៏ជាទីស្ថានសួគ៌លើមេឃរបស់ជនានុជនទាំងឡាយក្នុងលោក សូម្បីព្រះនរបតីទាំងឡាយ ព្រោះកុរុក្សេត្រជាស្ថានដ៏ពិសេសពន់ពេកក្រៃ។*

១៤. តន្នាមកីត៌្តនេនាបិ　　កោនាហ្យា សប្តមំ កុលមិ
　　កឹ បុនយ៌្យេ តុ សវ៌្វន្តេ　　មនុជា ធម៌្មពុទ្ធ្យះ [ធម៌ពុទ្ធិកាះ?]។

ប្រែថា៖ *ដោយគ្រាន់តែបានឮនូវកិត្តិនាម (របស់ស្ថានទីនោះ) បុណ្យក៏រមែងចម្រើនរហូតដល់សប្តកុល (ញាតិទាំង៧សន្តាន) ទៅហើយ ចុះទម្រាំតែមនុស្សមានពុទ្ធិទាំងឡាយណា (ដែលបានទៅកាន់ស្ថានទីនោះ) ជារឿយៗ តើនឹងបានបុណ្យច្រើនយ៉ាងណាទៅ?*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

## **ជ្រុងទី៤**

១៥.　អគ្វមេធសហស្រស្ស　　　រាជបេយសតស្ស ច
　　 គវាំ ឝតសហស្រស្ស　　　សម្យគ្ធត្តស្ស យត្ផលម៑។

ប្រែថា៖ *កាលបើបូជាយញ្ញអស្វមេធ (បូជាសេះ) រាប់ពាន់ដងក្តី និងបូជាយញ្ញរាជបេយ (គេសជ្ជៈនៃកម្លាំង ឬនៃសមរភូមិ) រាប់រយដងក្តី ឬបរិច្ចាគដ៏ប្រពៃសត្វគោរាប់សែន (១០០,០០០) ក្បាលក្តី អាចសម្រេចផលបានយ៉ាងណា។*

១៦.　តត្ផលំ តុ កុរុក្សេត្រេ　　　កាវ៌ត្តិ ស្មវជាតិយេ [ស្មវជាតិ យេ?]
　　 តត្រាប្យហេតុ ទុម្រ្សាបំ　　　លភន្តេ តេ ធ្រុវំ ផលម៑។

ប្រែថា៖ *ការសម្រេចផលដូចគ្នានោះ ក៏រមែងមានក្នុងកុរុក្សេត្រ។ ជនទាំងឡាយណាផ្ងួតជាអាទ័ក្នុងទីនោះ សូម្បីបានធ្វើបាបដ៏ទុយ៌ស ឬដោយគ្មានហេតុផលក្តី ពួកគេក៏គង់ទទួលបាននូវផល (ល្អវិញ) យ៉ាងឆាប់។*

១៧.　ឥត្យេវមាទិកុឝលំ　　　បូវ៌មុក្តំ សុរប៉ឹភិះ
　　 តទេវាត្រ កុរុក្សេត្រេ　　　លភន្តុ ពហវោ ជនាះ។

ប្រែថា៖ *កុសល (គុណជាតិកម្ចាត់បង់នូវអំពើបាប) (ដែលជាគុណសម្បត្តិ) មានជាអាទ៍ដូច្នេះ ត្រូវបានពោលទុកក្នុងកាលមុនហើយដោយពួកមហាឫថី និងទេពនិករទាំងឡាយ ហើយកុសល (ជាគុណជាតិកម្ចាត់បង់នូវអំពើបាបដែលជាគុណសម្បត្តិ) នោះ ប្រាកដណាស់ ក៏មាននៅក្នុងកុរុក្សេត្រ (ថ្មី) នេះដែរ ចូរជនានុជនទាំងឡាយទទួលបាន (នូវកុសលនោះ) ចុះ!*

១៨.　យានិ តីត៌សហស្រាណាំ　　　កុរុក្សេត្រេ ផលានិ ច
　　 អត្រ និក្ខេបតស្ថានិ　　　សន្តុ សន្និហិតានិ ច។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

ប្រែថា៖ *កាលបើតីថ៌រាប់ពាន់កន្លែងក្នុងកុរុក្សេត្រ (នោះ) មានផលសម្រេចបានដ៏ច្រើនយ៉ាងណា ចូរផលទាំងអម្បាលម៉ាននោះមកសណ្ឋិតនៅក្នុងកុរុក្សេត្រ (ថ្មី) នេះ កុំជាទីដទៃផ្សេងណាមួយឱ្យសោះ!*

១៩. អត្ថំយោជនមាយាមំ | អស្យ តីត៌្ថស្យ កីត៌្តិតមិ
យំ យំ ប្រេក្ឫមាគម្យ | ស មហាចាបចារេះ។

ប្រែថា៖ *ទំហំលាតសន្ធឹងកន្លះយោជន៍ជាប្រវែងរបស់តីថ៌ស្ថាន (នេះ) ធ្លាប់ត្រូវបានគេកោតសរសើរមកហើយថា ជនណាដែលបានមកកាន់ទីនេះ ពីស្រុកទេសណាៗក៏ដោយ ជននោះនឹងរមែងជាអ្នកបានរួចស្រឡះចាកមហាបាបទាំងឡាយបាន។*

២០. យេ តរីរបរិត្យាគំ | កុវ៌ន្តិ ស្នវនញ្ច យេ
យេ ត្ឫប្ត្ឫយា ច សេវន្តេ | បិវន្តិ ច សមាហិតាះ។

ប្រែថា៖ *ជនទាំងឡាយណាដែលបានលះបង់សរីរាង្គកាយ (ពីលោកនេះ) ក្ដី ជនទាំងឡាយណាដែលបានងូតទឹកក្ដី ជនទាំងឡាយណាដែលបានគោរពបម្រើដោយសេចក្ដីត្រេកត្រអាលក្ដី និងមានសមាហិតចិត្តក្រេបផឹកក្ដី។*

២១. យេឞាមគ្និមុខាឝីដាំ | ធាធាដាំ នៃកសំបធាមិ
ផលានិ យាន្យតេមាណិ | ច្រាប្នុវ្តាំ តានិ តេ ជជាះ។

ប្រែថា៖ *ផលទាំងឡាយកាលដែលបានធ្វើអគ្និមុខបូជាទាំងឡាយណាជាអាទិ៍ក្ដី កាលដែលបានឱ្យទានជាច្រើនដែលជាទ្រព្យសម្បត្តិមិនមែនត្រឹមតែមួយណាក្ដី ជនទាំងឡាយនោះត្រូវតែបានដល់នូវផលទាំងឡាយនោះ ដោយគ្មានសេសសល់ផលណាសោះឡើយ!*

២២. ចាបិម្នាឝិលបុរុមា | មុច្យន្តាំ ពហុចាបតាះ
កឹ បុនជ៌ម្មនិរតា | មហាតីត៌្ថនិមេវនាត៌។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

**ប្រែថា៖** *ពួកបុរសទាំងអស់ដែលមានបាបដ៏លាមក ជាបុគ្គលមានបាបច្រើន គប្បីបានរួចស្រឡះ! ចុះទំរាំបុគ្គលទាំងឡាយណាដែលស្និទ្ធនឹងព្រះធម៌ តើនឹងទទួលបានសេចក្តីចម្រើនយ៉ាងណាពីការស្នាក់នៅនាមហាតីថ៌ស្ថាននេះ?*

## មាលិនីឆន្ទ

២៣. កុសលជផលជាភជោតសភ្វ៌ទិក្កទេក   សម្បុកុជពលយកស្រ្បក្វាមចារុត្តមាង្គះ
ទុរជិតតមហាត្រីកន្ធកាស្តិត្ត៌មត្រៃ   ជនយតិ កុរិ ទេវានីក ឥត្យាប្តនាមា។

**ប្រែថា៖** *ព្រះរាជាព្រះអង្គមានស្រុកទេសគ្រប់តំបន់ បានស្រោចស្រពដោយផលធារ (លំហូរនៃសេចក្តីចម្រើនរុងរឿង) ដែលកើតចេញពីកុសល (គុណជាតិកម្ចាត់បង់នូវអំពើបាបទាំងពួង) ទ្រង់មានព្រះរូបកាយដ៏ឧត្តម និងស្រស់សង្ហា ទ្រង់ជាមកុដនៃយសសិរី និងមានអំណាចចេញពីសមត្ថភាពនៃព្រះកាយព្រះអង្គផ្ទាល់ ទ្រង់បានបង្កើតឱ្យមាននៅក្នុងលោកនេះនូវ* ***អគ្រមហាត្រីតន្ទុកតីថ៌*** *(តីថ៌ស្ថានដ៏ប្រសើរដែលប្រជុំដោយក្លិនក្រអូបនៃមហាសិរីសួស្តី) ដែលគេកសាងបានដោយកម្រក្រៃពេក (ដូច្នេះហើយ) ទើបទ្រង់បានទទួលព្រះគោរម្យនាមថា "**ទេវានីក**"។*

*សរុបជារួមមក ទោះបីយើងមិនដឹងច្បាស់ថា សិលាចារឹកវត្តហ្លួងកៅ បង្ហាញអំពីទិដ្ឋភាពព្រះបាទមហារាជាធិរាជទេវានីក ស្ថិតនៅក្នុងអាណាចក្រស្ម័យកាលមួយណាក៏ដោយ ខ្លឹមសារនិងអត្ថន័យរបស់សិលាចារឹក បានបញ្ជាក់ឱ្យឃើញអំពីឫទ្ធានុភាពរបស់ព្រះអង្គ និងគុណសម្បត្តិរបស់ទ្រង់ចំពោះការកសាងមហាតីថ៌ ដែលជាកន្លែងលាបជម្រះបាបនៃលទ្ធិព្រហ្មញ្ញសាសនា ហើយបានប្រៀបប្រដូចទីស្ថានមហាតីថ៌នោះ ទៅនឹងតំបន់កុរុក្សេត្រដែលគេស្គាល់ថាជាទីស្ថានពិសិដ្ឋរបស់អ្នកមានជំនឿលើព្រហ្មញ្ញសាសនាតាំងពីបុរាណរហូតមកទល់បច្ចុប្បន្ន។ បន្ថែមពីនេះ សិលាចារឹកនេះ គេចាត់ទុកថាជាសិលាចារឹកជាភាសាសំស្ក្រឹតដ៏ចំណាស់បំផុតដែលចារឹកជាភាសាសំស្ក្រឹត រកឃើញនៅតំបន់វត្តភូ ដែលអ្នកស្រាវជ្រាវមួយចំនួនយល់ថា ជាទឹកដីដំបូងនៃកំណើតអាណាចក្រចេនឡារបស់ខ្មែរ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ*

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

# ឯកសារយោង


Archaimbault, C. 1961. L’histoire de Čămpasăk [The history of Champasak]. *Journal Asiatique* [Asian journal] 249: 519–595.

Coedès, G. 1953. *Inscriptions du Cambodge [Inscriptions of Cambodia]*, Vol. 5. Paris: E. de Boccard.

Coedès, G. 1956. ‘Nouvelles données sur les origines du royaume khmèr: la stèle de Vàt Luong Kāu près de Vat P’hu’, *BEFEO*, Vol 48-1: 209-20.

Jacques, C. 1962. ‘Notes sur l’inscription de la stèle de Vat Luong Kau’, *Journal asiatique*, Vol 150:249-56.

Lunet de Lajonquière, E. 1907. *Inventaire descriptif des monuments du Cambodge.* Tome 2, Paris: E. Leroux,

Parmentier, H. 1913. ‘Complément à l’inventaire descriptif des monuments du Cambodge’, *BEFEO*, Vol 13: 1-64.

Vickery, M. 1998. *Society, Economics, and Politics in Pre-Angkor Cambodia: The 7th – 8th Centuries.* Tokyo: Center for East Asian Cultural Studies for UNESCO.

Zakharov, A.O. 2015. ‘Devānīka’s inscription from Vat Luong Kau near Vat Phou in Laos K.365: first English translation’, in *The South East Asian Review,* Vol. XL NOS 1-2, JAN-DEC, Edited by Sachchidanad Sahai.



Stèle de Vàt Luong Kau. Face A (*Nord*). [Photographie de la pierre.]

រូបលេខ១៖ ក្រដាសផ្តាមសិលាចារឹកវត្តហ្លួងកៅ មុខទី១ (ប្រភព៖ EFEO)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ



Stèle de Vat Luong Kau. Face B (*Ouest*). [Photographie d'un estampage.]

រូបលេខ២៤៖ ក្រដាសផ្តាមសិលាចារឹកវត្តហ្លួងកៅ មុខទី២ (ប្រភព៖ EFEO)



Stèle de Vát Luong Káu. Face C (*Sud*). [Photographie de la pierre.]

រូបលេខ៣៖ ក្រដាសផ្ដាមសិលាចារឹកវត្តហ្លួងកៅ មុខទី៣ (ប្រភព៖ EFEO)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ



Stèle de Vat Luong Kău, Face D (*Est*). [Photographie de la pierre.]

រូបលេខ២៤៖ ក្រដាសផ្តាមសិលាចារឹកវត្តហ្លួងកៅ មុខទី៤ (ប្រភព៖ EFEO)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន្ធ